UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

*សេចក្តីថ្លែងការណ៍ជាសាធារណៈ ២៥ កក្កដា ២០០៧*

## ***សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញអំពីច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ***

ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា សូមស្វាគមន៍សេចក្តីសំរេចដ៏មានសារសំខាន់របស់ក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើនៅពីថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ បញ្ជាក់ឡើងវិញថា នៅពេលបកស្រាយច្បាប់ និងជំនុំជំរះក្តី តុលាការនៅកម្ពុជាត្រូវតែពិចារណាពីការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ក្រុមប្រឹក្សាធម្មនុញ្ញបានសំរេចថា ច្បាប់ស្ថានទំងន់ទោសនៃបទឧក្រិដ្ឋឆ្នាំ២០០២ គ្មានបំណងរំលត់ការការពារដែលផ្តល់ដល់ជនល្មើសដែលជាអនីតិជនដោយមាត្រា៦៨ នៃបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ឆ្នាំ១៩៩២ នោះទេ ហើយចៅក្រមត្រូវបន្តយកមកពិចារណាពីអាយុរបស់ជនល្មើស នៅពេលថ្លឹងថ្លែងទោសឱ្យបានសមរម្យក្នុងរឿងក្តីទាក់ទងនឹងជនល្មើសអាយុក្រោម១៨ឆ្នាំ អនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

មាត្រា៦៨ នៃបទប្បញ្ញត្តិច្បាប់អ៊ុនតាក់តំរូវអោយចៅក្រមពិចារណាពីធាតុផ្សំសំរាលទោស ដូចជាអាយុ និងស្ថានភាពសរសៃប្រសាទរបស់ទណ្ឌិត នៅពេលធ្វើការផ្តន្ទាទោស ហើយណែនាំចៅក្រមអោយបន្ធូរបន្ថយទោសរហូតដល់ពាក់បណ្តាលចំពោះជនល្មើសដែលមានអាយុក្រោម១៨ឆ្នាំ ។ បទប្បញ្ញត្តិនេះអនុវត្តតាមមាត្រា ៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលចែងថា ការផ្តន្ទាទោសដាក់ពន្ធនាគារ ត្រូវធ្វើឡើងតែក្នុងករណីពិសេស ហើយសំរាប់តែជាវិធានការចុងក្រោយ និងសំរាប់តែរយៈពេលខ្លីបំផុតតាមការចាំបាច់ប៉ុណ្ណោះ ។ អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានធានាការពារដោយមាត្រា ៣១ និង ៤៨ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា៨ នៃច្បាប់ស្តីពីស្ថានទំងន់នៃបទឧក្រិដ្ឋ បានលប់បំបាត់ពីលទ្ធភាពរបស់ចៅក្រមក្នុងការពិចារណាពីស្ថានសំរាលទោសដើម្បីបន្ធូរបន្ថយ ឬព្យួរទោសនៅក្នុងរឿងក្តីបទឧក្រិដ្ឋ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានស្នើសុំឱ្យ

10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342; Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ពិនិត្យមាត្រានេះថាតើស្របនឹងរដ្ឋធម្មនុញ្ញឬទេ ពីព្រោះមាត្រានេះហាក់ដូចជាបានរំលោភមាត្រា៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ចាប់តាំងពីការប្រកាសអោយប្រើក្នុងខែមករា ឆ្នាំ២០០២ ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋបានបង្កើតនូវភាពមិនជាក់លាក់ផ្នែកច្បាប់សំរាប់ពិចារណាក្នុងរឿងក្តីអនីតិជន ។ ចៅក្រមនៅតាមតុលាការមួយចំនួនបានផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងធ្ងន់ធ្ងរដល់អនីតិជន ថ្វីបើមានតំរូវការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារក៏ដោយ ។ ចំណែកចៅក្រមមួយចំនួនទៀតនៅតែបន្តអនុវត្តតាមមាត្រា៦៨ នៃបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ ដោយអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ការអនុវត្តន៏ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋនៅក្នុងរឿងក្តីអនីតិជន បង្ហាញពីការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដែលមិនសមាមាត្រចំពោះកុមារដែលប្រឈមមុខនឹងច្បាប់ ។ ជាឧទាហរណ៏ ក្មេងប្រុសពីរនាក់មានពិរុទ្ធភាពពីបទលួច(ប្លន់)ស្បែកជើងផ្ទាត់មួយគូ ត្រូវទទួលទោសជាប់ពន្ធនាគារវែងជាងនីតិជនម្នាក់ដែលលួចម៉ូតូមួយគ្រឿង ។

ឥលូវនេះក្រុមប្រឹក្សាធម្មនុញ្ញបានសំរេចហើយថា ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋឆ្នាំ២០០២ មិនអធម្មនុញ្ញភាពទេ ដោយសារច្បាប់នេះមិនដែលមានបំណងអនុវត្តចំពោះអនីតិជននោះទេ អាស្រ័យហេតុនេះហើយច្បាប់នេះ មិនផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារទេ ។ ក្នុងការសំរេចសេចក្តីដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើអោយចៅក្រមច្បាស់លាស់ទាំងអស់គ្នាម្តងទៀត ក្នុងការយកអាយុរបស់ជនល្មើសមកពិចារណា និងធ្វើការផ្តន្ទាទោសដែលស្រាលជាង ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានស្តារស្ថានភាពស្របច្បាប់ក្នុងការអនុវត្តន៏ ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងពង្រឹងការការពារសិទ្ធិធម្មនុញ្ញរបស់កុមារតាមនីតិរដ្ឋ ។ ក្រុមប្រឹក្សាធម្មនុញ្ញ ក៏គូសបញ្ជាក់ដោយដាច់ណាត់ពីទីតាំងនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិថាជាផ្នែកមួយនៃច្បាប់កម្ពុជា ការពារដោយរដ្ឋធម្មនុញ្ញ ហើយក្រុមប្រឹក្សានេះ ធ្វើការសំរេចពីចំនុចយ៉ាងសំខាន់ថា ចៅក្រមត្រូវពិចារណាពីបញ្ហាសិទ្ធិមនុស្សជាមូលដ្ឋាននៅពេលពិចារណាលើរឿងក្តី ។

ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ទន្ទឹងមើលចៅក្រមទាំងអស់ធ្វើការកត់ចំណាំសេចក្តីសំរេចនេះ ហើយយកមកអនុវត្តអោយបានទាំងអស់គ្នា ។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក៏ទទូចអោយមានការអនុម័តឱ្យបានឆាប់នៃច្បាប់ស្តីពីយុត្តិធមិអនីតិជន ដែលសព្វថ្ងៃនេះកំពុងតែរៀបរៀងដោយក្រសួងយុត្តធមិ សហការជាមួយអង្គការយូនីសេហ្វ ដើម្បីពង្រឹងការការពារសិទ្ធិកុមារបន្ថែមទៀតនៅក្នុងប្រព័ន្ធយុត្តិធមិកម្ពុជា ។

ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា នៅតែបារម្ភពីស្ថានភាពរបស់ជនដែលគ្មានសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយសារបញ្ហាសុខភាពសរសៃប្រសាទតាមច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ហើយសង្ឃឹមថា មាត្រា៦៨នៃបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ នឹងនៅតែបន្តអនុវត្តនៅក្នុងរឿងក្តីបែបនេះ។

*សូមភ្ជាប់មកជាមួយសេចក្តីប្រកាសព័ត៌មាន នូវសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និងសំរង់នៃបទបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ។*

*<u>កំណត់សំគាល់</u>: ទោះបីជាសេចក្តីសំរេចនេះយោងដល់មាត្រា៧០ ជាជាងមាត្រា៦៨ នៃបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ក៏ដោយ ក៏នេះគឺជាការបញ្ជាក់ច្បាស់ថាសំដៅដល់មាត្រា៦៨ដែរ បើអនុលោមតាមព្រះរាជសាររបស់ព្រះករុណាជីវិតតំកល់លើត្បូង ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧។ ការភាន់ច្រឡំនេះមិនប៉ះពាល់ដល់ខ្លឹមសារនៃសេចក្តីសំរេចនេះទេ។*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

**លេខ :១៣១ /០០៣ /២០០៧**

**ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧**

**សេចក្តីសម្រេច**

**លេខ :០៩២/០០៣/២០០៧ កបធ.ច**

**ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧**

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជសារ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ វេលាម៉ោង ១៤ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាតាមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

- យល់ឃើញថា មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋបានចែងថា " ចំពោះបទឧក្រិដ្ឋ និងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬព្យួរទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើស មិនត្រូវទទួលរង

ទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុនៗក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន " ។

- យល់ឃើញថា មាត្រា ៨ នេះ កែប្រែតែមាត្រា ៧០ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល **ពុំមានប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កុមារឡើយ** ។ បទបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋខាងលើនេះ ពុំមានអធម្មនុញ្ញភាពទេ ។
- យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់ ។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## សម្រេច

**មាត្រា ១**.-មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២**.-សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល